# ឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមនិងតម្រូវការយុត្តិធម៌

## សុន្ទរកថារបស់លោកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ចូសេហ្វ មូសូមេលី នៅក្នុងឱកាសជួបសំណេះសំណាលជាមួយនឹងជនរងគ្រោះដោយរបបខ្មែរក្រហម នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៦

ឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មដ៏ធំបំផុតប្រចាំសតវត្សរ៍ទី២០ បានកន្លងទៅដោយមិនមានការដាក់ទណ្ឌកម្មរហូតដល់៣០ ឆ្នាំ ។ ដូចដែលលោក-លោកស្រីបានជ្រាបហើយក្នុងចន្លោះពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៨ មករា ឆ្នាំ១៩៧៩ គឺក្នុងរយៈពេលតែជិតបួនឆ្នាំប៉ុណ្ណោះ របបខ្មែរក្រហមបានធ្វើទារុណកម្ម បង្អត់អាហារ និងសម្លាប់ (“កម្ទេច” គឺជាពាក្យដែលខ្មែរក្រហមចូលចិត្តប្រើ) ប្រជាជនកម្ពុជាអស់២,២លាននាក់ ។ ចំនួននេះស្មើនឹងចន្លោះពីមួយភាគបួនទៅមួយភាគបីនៃចំនួនប្រជាជនទាំងអស់ ។ គ្មាននរណាម្នាក់បានរួចខ្លួនពី“អ្នករំដោះប្រជាជន” ទាំងអស់នេះទេ ។ បញ្ជីរាយនាមសត្រូវរបស់ខ្មែរក្រហមវែងណាស់ រួមមានជនជាតិអ៊ីស្លាម ជនជាតិភាគតិចវៀតណាម ព្រះសង្ឃ អ្នកទីក្រុង អ្នកដែលមានសញ្ញាប័ត្រ អ្នកពាក់វ៉ែនតា ជាពិសេសកម្មាភិបាលខ្មែរក្រហមខ្លួនឯងដែលត្រូវអង្គការសង្ស័យថាក្បត់ដែរ ។ ក្រុមទាំងនេះនិងអ្នកដទៃជាច្រើនទៀត រួមមាន ភរិយា ស្វាមី និងកូន ត្រូវបានកម្ចាត់ទាំងឫសនៅក្នុងរបបប្រល័យពូជសាសន៍ដែលសាហាវបំផុតមិនធ្លាប់មានពីមុនមក ។

ហេតុអ្វីបានជាខ្ញុំនិយាយថា “ជារបបប្រល័យពូជសាសន៍ដែលមិនធ្លាប់មាន” នៅពេលដែលពិភពលោកមានការប្រកួតប្រជែងយ៉ាងតឹងតែងហើយដែលជួនកាលហាក់ដូចជាបាត់បង់អស់នូវគុណធម៌និងសេចក្តីអាណិតអាសូរចំពោះអ្នកដទៃដូច្នេះ? ពីព្រោះនេះជារបបប្រល័យពូជសាសន៍តែមួយគត់ដែលមិនបាននាំអ្នកជាប់ទោសចំពោះបទក្រិដ្ឋនេះមកទទួលខុសត្រូវចំពោះមុខច្បាប់ឡើយ ។ ក្នុងករណីអំពើប្រល័យពូជសាសន៍នៅ បូស្នៀរ សៀបប៊ី លីបេរី អេត្យូពី និង រ៉ាន់ដា ជនរងគ្រោះ ក្រុមគ្រួសាររបស់ជនរងគ្រោះ និងសហគមន៍អន្តរជាតិ សុទ្ធតែបានទទួលយុត្តិធម៌ និងបានសង់សឹកនៅក្នុងកម្រិតណាមួយតាមរយៈសាលាក្តីនូរឹមប៊ឺក និងសវនាការថ្នាក់ជាតិ និងអន្តរជាតិក្រោយៗទៀត ប៉ុន្តែករណីដូចគ្នានេះមិនបានកើតឡើងនៅប្រទេសកម្ពុជាទេ ។

ថ្មីៗនេះ យើងបានឃើញមានការរីកចម្រើនខ្លះក្នុងការបង្កើតសាលាក្តីខ្មែរក្រហម ដោយមានកិច្ចសហការជាមួយអង្គការសហប្រជាជាតិ ប៉ុន្តែយើងមានពេលវេលាកាន់តែតិចទៅៗ ដោយសារឃាតកទាំងនោះមានវ័យកាន់តែចាស់ និងស្លាប់ជាបណ្តើរៗ ប៉ុន្តែការឈឺចាប់


ជនរងគ្រោះនៅរបបខ្មែរក្រហមជួបសំណេះសំណាលជាមួយលោកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកនៅនិវេសនដ្ឋានរបស់លោក ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៦

និងរន្ធត់ដែលខ្មែរក្រហមបង្កឡើងមិនគួរនឹងបណ្តោយឲ្យបាត់បង់ទៅមិនគួរបណ្តោយឲ្យរលុបបាត់ឡើយ ។

តើតុលាការនេះមានប្រយោជន៍អ្វី? អ្នកខ្លះនិយាយថា ការចំណាយថវិកាដែលមានតិចតួចទៅលើឧក្រិដ្ឋកម្មដែលមានចំណាស់ ៣០ឆ្នាំទៅហើយ ក្នុងខណៈពេលដែលប្រទេសកម្ពុជាទទួលរងនូវបញ្ហាបន្ទាន់ផ្សេងទៀតជាច្រើននោះ ជារឿងមួយដែលមិនស័ក្តិសម ។ ខ្ញុំសង្ឃឹមថា ប្រជាជនកម្ពុជាភាគច្រើនមិនយល់ស្របនឹងការអះអាងទេ ។ ក្នុងប្រទេសកម្ពុជា ប្រជាជនកម្ពុជាភាគច្រើនមិនយល់ស្របនឹងការអះអាងនេះទេ ។ ក្នុងប្រទេសកម្ពុជា អ្នកដែលបានប្រព្រឹត្តបទឧក្រិដ្ឋប្រល័យពូជសាសន៍ទាំងនោះភាគច្រើនរស់នៅយ៉ាងសុខសាន្ត មានសេរីភាព ថែមទាំងហ៊ឺហាទៀតផង ជាមួយនឹងជនរងគ្រោះដែលខ្លួនបានធ្វើបាប ។ មិនមានគ្រួសារណាមួយក្នុងប្រទេសកម្ពុជា ដែលមិនរងគ្រោះពីរបបប្រល័យពូជសាសន៍នោះឡើយ ។ អ្នករាល់គ្នាដែលមានជីវិតនៅថ្ងៃនេះ សុទ្ធតែមាន ឪពុក ម្តាយ បងប្អូន មីង និងពូ បានស្លាប់នៅក្នុងការសម្លាប់រង្គាលនោះ ។


លោកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ចូសេហ្វ មូសូមេលី

ខ្មែរក្រហមបានប្រកាសថា ខ្លួននឹងនាំប្រទេសកម្ពុជាទៅកាន់ "ឆ្នាំសូន្យ" ។ ខ្មែរក្រហមបានរក្សាពាក្យសន្យារបស់ខ្លួនបានយ៉ាងល្អ ហើយនៅពេលនោះគឺ៣០ឆ្នាំក្រោយមកប្រទេសនេះនៅតែបាត់បង់និងបាក់បែកនៅឡើយ ។ ការបែកបាក់របស់ប្រទេសកម្ពុជាមិនមែនដោយសារតែនយោបាយនិងសេដ្ឋកិច្ចប៉ុណ្ណោះទេ វាជាការបែកបាក់នូវប្រព័ន្ធច្បាប់ផ្លូវចិត្តនិងស្មារតី ។ រាល់កំហុសឆ្គងទាំងឡាយក្នុងសង្គមកម្ពុជាបច្ចុប្បន្នរួមមានការជួញដូរមនុស្ស ការជួញដូរថ្នាំញៀន ការលួចបន្លំធនធាននិងវប្បធម៌ និងអំពើពុករលួយដែលជ្រៀតចូលទៅគ្រប់ស្រទាប់រដ្ឋាភិបាល ទាំងអស់នេះសុទ្ធតែត្រូវបានធ្វើឲ្យកាន់តែធ្ងន់ធ្ងរឡើងដោយសារបរាជ័យរបស់សហគមន៍អន្តរជាតិក្នុងការនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោសចំពោះមុខច្បាប់ ។

វប្បធម៌និទណ្ឌភាពដែលយើងឃើញនៅក្នុងសង្គមកម្ពុជាសព្វថ្ងៃបានចាក់ឫសយ៉ាងជ្រៅទៅក្នុងជំនឿដែលមិនអាចប្រកែកបានរបស់ប្រជាជនកម្ពុជាដែលជឿថា គ្មានបទល្មើសណាដែលធំរហូតដល់ថ្នាក់ចាំបាច់ត្រូវតែទទួលទណ្ឌកម្មនោះទេ ហើយថា ទោះជាប្រជាជនកម្ពុជាណាម្នាក់ធ្វើអ្វីក៏ដោយ ក៏មិនមានបញ្ហាអ្វីដែរ ពីព្រោះវាមិនមានអ្វីដែលអាក្រក់ជាងអ្វីដែលខ្មែរក្រហមធ្វើនោះទេ ។ សាលាក្តីខ្មែរក្រហមជាជំហានចាំបាច់ដំបូងដើម្បីព្យាបាលរបួសដែលមានចំណាស់៣ ទសវត្សរ៍ ដែលនៅមិនទាន់ជាសះស្បើយនៅឡើយ ។ ការរាំងស្ទះដល់ការរីកចម្រើននិងកំណែទម្រង់របស់ប្រទេសកម្ពុជានឹងនៅតែមានលុះត្រាណាតែយុត្តិធម៌ក្នុងកម្រិតណាមួយត្រូវបានរកឃើញ ។ អ្នកទាំងឡាយដែលបានស្លាប់និងទទួលរងគ្រោះមរណភាពនិងការឈឺចាប់របស់គាត់ត្រូវតែបានទទួលស្គាល់ថាជាការពិតនិងត្រូវតែបានគោរពបូជា ។ ជនរងគ្រោះនៃរបបខ្មែរក្រហមសមនឹងទទួលបាននូវយុត្តិធម៌ ។ ជនរងគ្រោះនៃរបបប្រល័យពូជសាសន៍ទាមទារឲ្យមានយុត្តិធម៌ ។ វាជាសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានយុត្តិធម៌ ហើយវាជាកាតព្វកិច្ចរបស់យើងក្នុងការធានាឲ្យមានយុត្តិធម៌ ។